ស្ថានទូតជប៉ុន

ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 30 PR-18/EoJ

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៨

## កម្មវិធីសហប្រតិបត្តិការអ្នកជិះនាវាជប៉ុន-អាស៊ានលើកទី២
## គំនិតផ្តួចផ្តើមទស្សនៈទីក្រុងវៀងចន្ទន៍

ក្រសួងការពារជាតិជប៉ុន បានដឹកនាំកម្មវិធីសហប្រតិបត្តិការអ្នកជិះនាវាជប៉ុន-អាស៊ានលើកទី២ នៅលើនាវាមួយគ្រឿង នៃកងកម្លាំងស្វ័យការពារជើងទឹកជប៉ុន មានឈ្មោះថា OSUMI ពីថ្ងៃទី ១០ ដល់ ១៥ ខែឧសភា ឆ្នាំ២០១៨។ កម្មវិធីដែលមានការចូលរួមពីសមាជិកអាស៊ានទាំងអស់នេះ ត្រូវបានរៀបចំឡើងជាមួយនឹងគំនិតផ្តួចផ្តើមក្រោម "ទស្សនៈទីក្រុងវៀងចន្ទន៍ " ដែលត្រូវបានប្រកាសដោយប្រទេសជប៉ុន ។ អនុលោមតាមគោលការណ៍ណែនាំនៅក្នុងទស្សនៈទីក្រុងវៀងចន្ទន៍ កម្មវិធីនេះ ផ្តល់ឱកាសសម្រាប់អ្នកចូលរួមដើម្បីជម្រុញការយល់ដឹងអំពីគ្នាទៅវិញទៅមក និងកសាងបណ្តាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាពពាក់ព័ន្ធនឹងសន្តិសុខសមុទ្រ និងចែករំលែកការយល់ដឹងអំពីច្បាប់សមុទ្រអន្តរជាតិ ក្នុងគោលបំណងរួមចំណែកដល់ការលើកកម្ពស់ស្ថិរភាពនៅក្នុងតំបន់។

### សេចក្តីលំអិតនៃកម្មវិធី

**១. មាតិការ**

កម្មវិធីនេះរួមមានសិក្ខាសាលាស្តីពីជំនួយមនុស្សធម៌ និងការជួយសង្គ្រោះពេលមានគ្រោះមហន្តរាយ ច្បាប់សមុទ្រអន្តរជាតិ និងឱកាសដើម្បីសង្កេតមើលសកម្មភាពបណ្តុះបណ្តាលផ្សេងៗ ។

**២. អ្នកចូលរួម**

តំណាងផ្នែកយោធាមួយរូបពីប្រទេសជាសមាជិកអាស៊ាននិមួយៗ (ខាងកម្ពុជា មានលោកអនុនាវីទោ **លី គុណហេង** បានចូលរួមក្នុងកម្មវិធីនេះ) ។

**៣. រយៈពេលនៃកម្មវិធី**

ពីថ្ងៃទី ១០ ដល់ ១៥ ខែឧសភា ឆ្នាំ ២០១៨ ។

**៤. ទីកន្លែង**

ពីសាធារណរដ្ឋឥណ្ឌូណេស៊ី ដល់ប្រទេសម៉ាឡេស៊ី (នៅលើនាវា JS OSUMI)